00799559

E178/1

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 11 / 04 / 2012
ម៉ោង (Time/Heure): 13:45
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

# អនុស្សរណៈ-អង្គជំនុំជម្រះសាលាដំបូង

ថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១២

**ជូនចំពោះ:** ភាគីទាំងអស់នៃសំណុំរឿង ០០២

**ពី:** **ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង**

**ចម្លងជូន:** លោក/លោកស្រីចៅក្រមទាំងអស់នៃអង្គជំនុំជម្រះសាលាដំបូង; មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង

**កម្មវត្ថុ:** សំណើរបស់មេធាវីការពារជនជាប់ចោទ ខៀវ សំផន ស្នើសុំបញ្ជាក់អំពីប្រភេទនៃឯកសារ E3 ជាក់លាក់មួយចំនួន (ឯកសារ E178) និងសំណើសុំ E167

១. អង្គជំនុំជម្រះសាលាដំបូងបានទទួលសំណើមួយពីមេធាវីការពារជនជាប់ចោទ ខៀវ សំផន ដែលស្នើសុំបំភ្លឺអំពីប្រភេទនៃចំណាត់ថ្នាក់ឯកសារដែលមានលេខសម្គាល់ E3 ("លេខ E3") (ឯកសារ E178)។ អង្គជំនុំជម្រះក៏បានទទួលសំណើដាច់ដោយឡែកមួយ ដែលក្នុងនោះមេធាវីការពារជនជាប់ចោទ ខៀវ សំផន លើកបញ្ហាស្រដៀងគ្នា (E167)។ អង្គជំនុំជម្រះឆ្លើយតបតាមរយៈអនុស្សរណៈ ដោយហេតុថា បញ្ហាដែលមេធាវីការពារជនជាប់ចោទ ខៀវ សំផន បានលើក គឺជាបញ្ហាពាក់ព័ន្ធតែនឹងការរៀបចំ ឬជាសំណើសុំការបញ្ជាក់បំភ្លឺប៉ុណ្ណោះ ហើយពុំពាក់ព័ន្ធទៅនឹងបញ្ហាអង្គហេតុ ឬបញ្ហាអង្គច្បាប់ថ្មីឡើយ។ នៅដំណាក់កាលដំបូង អនុស្សរណៈទាំងនេះត្រូវបានធ្វើជាភាសាអង់គ្លេសប៉ុណ្ណោះ ក្នុងប្រភេទជាសេចក្តីជូនដំណឹងក្រៅផ្លូវការជាមុន ដោយអង្គជំនុំជម្រះយល់ថា ភាគីត្រូវការព័ត៌មានជាបន្ទាន់ ប៉ុន្តែអនុស្សរណៈទាំងនេះក៏ត្រូវបានដាក់ជាភាសាខ្មែរ និងភាសាបារាំងផងដែរ នៅពេលបន្ទាប់។

២. អង្គជំនុំជម្រះសូមបញ្ជាក់ថា ការដាក់លេខ E3 បញ្ជាក់ថា ឯកសារមួយត្រូវបានដាក់នៅចំពោះមុខអង្គជំនុំជម្រះ ឬចំពោះមុខភាគីដោយពុំមានការជំទាស់នោះទេ (ឬ ក្នុងករណីដែលមានការជំទាស់ទៅនឹងឯក-សារណាមួយ តែការជំទាស់នោះត្រូវបានអង្គជំនុំជម្រះបដិសេធ)។ ដោយអនុលោមតាមវិធាន ៨៧(២) និងវិធាន ៨៧(៣) អង្គជំនុំជម្រះអាចធ្វើសេចក្តីសម្រេចរបស់ខ្លួន ដោយផ្អែកលើឯកសារនានាដែលត្រូវបានដាក់នៅចំពោះមុខអង្គជំនុំជម្រះ ឬភាគី (*ដូចជា* "ខ្លឹមសាររបស់ឯកសារទាំងនោះត្រូវបានសង្ខេប អាន ឬបង្ហាញអត្តសញ្ញាណសមស្របនៅក្នុងតុលាការ") "ដែលត្រូវឆ្លងកាត់ការដេញដោល" និងពុំត្រូវបានដកចេញនូវហេតុផលណាមួយ ក្នុងចំណោមហេតុផលទាំង ៥ ដែលមានចែងក្នុងវិធាន ៨៧(៣)(ក) ដល់ (ង) ឡើយ។ អង្គជំនុំជម្រះចាត់ទុកថា ឯកសារបានឆ្លងកាត់ការដេញដោលរួចហើយ ប្រសិនបើឱកាសគ្រប់គ្រាន់ត្រូវបានផ្តល់ទៅភាគីដើម្បីជំទាស់ទៅនឹងការយកឯកសារនេះមកប្រើប្រាស់ ទោះបីភាគីប្រើ ឬពុំប្រើប្រាស់ឱកាសនេះក៏ដោយ។ ឯកសារថ្មីៗដែលអង្គជំនុំជម្រះយល់ថាបានបំពេញលក្ខខណ្ឌ ដូចមានក្នុងវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង ក៏ត្រូវបានដាក់លេខ E3 ផងដែរ។ ការដាក់លេខ E3 ត្រូវបានកត់ត្រាដោយក្រឡាបញ្ជីនៅក្នុងកំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី សម្រាប់ថ្ងៃនីមួយៗនៃសវនាការ ហើយក៏នឹងត្រូវបានជូនដំណឹងនាពេលឆាប់ៗទៅភាគី តាមរយៈកម្មវិធីឯកសារស្តីពីសវនាការប្រចាំថ្ងៃ (Daily Trial Document Interface)។ នៅពេលត្រូវបានដាក់លេខ E3 រួចហើយ ឯកសារដែលមានលេខ E3 នឹងជំនួសលេខឯកសារមុនៗដែលធ្លាប់ត្រូវបានដាក់ឱ្យឯកសារនោះ។

៣. ក្នុងអំឡុងពេលដំបូងៗនៃសវនាការ និងដោយមូលហេតុពិសេស អង្គជំនុំជម្រះក៏បានដាក់លេខ E3 សម្រាប់ឯកសារខ្លះដែលត្រូវបានដាក់នៅចំពោះមុខអង្គជំនុំជម្រះ ឬភាគី ប៉ុន្តែដែលនៅដំណាក់កាលនោះ ពុំបានឆ្លងកាត់ការដេញដោលទេ។ ករណីបែបនេះទាក់ទិននឹងឯកសារចំនួន ១២៤ ដែលត្រូវបានយោងនៅក្នុងជើងទំព័រនៃដីកាដំណោះស្រាយ (ឯកសារ D427) ដែលត្រូវបានដាក់នៅចំពោះមុខអង្គជំនុំជម្រះ និងត្រូវបានដាក់លេខ E3 ក្នុងអំឡុងកិច្ចដំណើរការសវនាការកាលពីថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០១១ ប្រយោជន៍ដើម្បីការរៀបចំសវនាការប្រកបដោយប្រសិទ្ធភាព (E159)។ ប៉ុន្តែនៅពេលក្រោយមកទៀត ភាគីត្រូវបានផ្តល់ឱកាសដើម្បីលើកការជំទាស់ទៅនឹងឯកសារទាំងនោះកាលពីថ្ងៃទី ១៦ ខែ មករា ឆ្នាំ ២០១២។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះចាត់ទុកថា នៅពេលនេះ ឯកសារទាំងនេះបានឆ្លងកាត់ការដេញដោលរួចហើយ។ សេចក្តីសម្រេចចុះថ្ងៃទី ០៩ ខែ មេសា ឆ្នាំ ២០១២ (ឯកសារ E185) របស់អង្គជំនុំជម្រះបានសម្រេចលើការជំទាស់នានាទៅនឹងឯកសារទាំងអស់នេះ ក្នុងចំណោមបញ្ហាផ្សេងៗទៀត។

00799561

E178/1

៤. នៅក្នុងសំណើរបស់ខ្លួន មេធាវីការពារជនជាប់ចោទ ខៀវ សំផន បានស្នើសុំការបញ្ជាក់បំភ្លឺអំពីប្រភេទនៃ "ឯកសារចំនួន ០៨ ក្នុងចំណោមឯកសារចំនួន ១៣ ដែលពីមុនពុំមែនជាឯកសារលេខ E3 ដែលត្រូវបានបង្ហាញ" ដោយសហព្រះរាជអាជ្ញា ក្នុងអំឡុងកិច្ចដំណើរការសវនាការកាលពីថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ២០១២ (ឯកសារ E178 កថាខណ្ឌ ៥)។ តាមការពិត សហព្រះរាជអាជ្ញាបានយោងទៅដល់ឯកសារចំនួន ០៩ ដាច់ដោយឡែកពីគ្នា កាលពីថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ២០១២ ដែលក្នុងនោះឯកសារចំនួន ០៣ ត្រូវបានដាក់លេខ E3 រួច ហើយ[1]។ ក្នុងចំណោមឯកសារទាំង ០៦ ដែលត្រូវបានដាក់លេខ E3 កាលពីថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ២០១២ ភាគីធ្លាប់ត្រូវបានផ្តល់ឱកាសកាសដើម្បីជំទាស់ទៅនឹងឯកសារចំនួន ០៤ នៅរវាងថ្ងៃទី ១៧ និងថ្ងៃទី ១៩ ខែ មករា ឆ្នាំ ២០១២ (ឯកសារ E159)[2]។ អង្គជំនុំជម្រះបានទុកឱកាសឱ្យភាគីដើម្បីជំទាស់ទៅនឹងឯកសារចំនួន ០២ ដែលនៅសល់ នៅរវាងថ្ងៃទី ១២ និងថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០១២ (ឯកសារ E172/5)[3]។ ហេតុដូច្នេះ នៅថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០១២ ឯកសារទាំង ០៦ ដែលសហព្រះរាជអាជ្ញាបានបង្ហាញ និងបានដាក់លេខ E3 កាលពីថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ២០១២ ត្រូវបានចាត់ទុកថាបានដាក់នៅចំពោះមុខអង្គជំនុំជម្រះ និងបានឆ្លងកាត់ការជជែកដេញដោល។ អង្គជំនុំជម្រះក៏បានសម្រេចលើការជំទាស់នានាទៅនឹងឯកសារចំនួន ០៤ ក្នុងចំណោមឯកសារទាំងនេះនៅក្នុងសេចក្តីសម្រេចរបស់ខ្លួន ចុះថ្ងៃទី ០៩ ខែ មេសា ឆ្នាំ ២០១២ (ឯកសារ E185) ហើយអង្គជំនុំជម្រះនឹងសម្រេចលើឯកសារដែលនៅសេសសល់ នាពេលសមស្របខាងមុខ។

៥. នៅក្នុងសំណើដាច់ដោយឡែកមួយ (ឯកសារ E167) មេធាវីការពារជនជាប់ចោទ ខៀវ សំផន យោងទៅលើឯកសារនានាដែលត្រូវបានយោងនៅក្នុងជើងទំព័រនៃដីកាដំណោះស្រាយ ថាជាឯកសារពាក់ព័ន្ធទៅនឹងចំណុចអង្គហេតុទីមួយ និងទីពីរនៃសវនាការនាពេលបច្ចុប្បន្ន (*ដូចជា* "ប្រវត្តិសវតារ" និង "រចនាសម្ព័ន្ធរដ្ឋបាល និងរចនាសម្ព័ន្ធនៃការប្រាស្រ័យទាក់ទងការងារ និងតួនាទីខ្លះរបស់ជនជាប់ចោទ" (ឯកសារ E155) និងពាក់ព័ន្ធនឹងចំណុចដែលថាមកទល់នឹងពេលបច្ចុប្បន្ន ពុំទាន់មានអ្នកជំនាញណាម្នាក់ត្រូវបានស្តាប់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះឡើយ។ សំណើនេះចោទសួរថា តើគេពិតជាអាចនិយាយថា ចំណុចអង្គហេតុនៃសវនាការពាក់ព័ន្ធនឹងប្រវត្តិសវតារត្រូវបានបញ្ចប់ដែរ ឬយ៉ាងណា (កថាខណ្ឌ ១១-១៥)។ ដោយហេតុថា

[1] ឯកសារទាំង ៩ ដែលសហព្រះរាជអាជ្ញាបានលើកគឺ ឯកសារ D56-Doc.060, ឯកសារ D243/2.1.9 (ឯកសារE3/25), ឯកសារ D189.2, ឯកសារ D313/1.2.38, ឯកសារ D313/1.2.32, IS 20.30, IS 13.9, IS 6.2 (E3/99) និងឯកសារ D262.26 (E3/147)។

[2] មានដូចជា D56-Doc.060, D189.2, IS 20.30 និង IS 13.9។

[3] មានដូចជា ឯកសារ D313/1.2.38 និង D313.1.2.32។

នៅពេលនេះមេធាវីការពារជនជាប់ចោទ ខៀវ សំផន គួរអាចយល់បានតាមរយៈអនុស្សរណៈស្តីពីសវនាការ និងការរៀបចំសវនាការជាបន្តបន្ទាប់ ការបែងចែកសវនាការជាច្រើនវគ្គគឺធ្វើឡើង ដើម្បីណែនាំភាគីពាក់ព័ន្ធនឹងការផ្តោតការយកចិត្តទុកដាក់ជាចម្បងទៅលើវគ្គនីមួយៗ និងដើម្បីផ្តល់ឱកាសឲ្យភាគីបញ្ជាក់អំពីឯកសារសំខាន់ៗឲ្យបានតាមលំដាប់លំដោយត្រឹមត្រូវ និងទៅតាមដំណាក់កាលសមស្រប។ ផ្ទុយទៅនឹងអ្វីដែលត្រូវបានលើកក្នុងឯកសារ E167 ការបែងចែកសវនាការជាដំណាក់កាលមានគោលបំណងដើម្បីផ្តល់រចនា សម្ព័ន្ធត្រឹមត្រូវមួយដល់ការជំនុំជម្រះលើសំណុំរឿង០០២/០១ និងពុំធ្វើឲ្យប៉ះពាល់ឡើយដល់ ក) ការស្តាប់សក្ខីកម្មរបស់អ្នកជំនាញនៅពេលក្រោយអំពីប្រធានបទទាំងអស់ពាក់ព័ន្ធនឹងសំណុំរឿង ០០២/០១ (រួមទាំងចំណុចអង្គហេតុដែលអង្គជំនុំជម្រះកំណត់ឲ្យធ្វើសវនាការកាលពីពេលមុននោះ) ខ) សមត្ថភាពរបស់ក្នុងការសួរសំណួរទៅសាក្សីពុំមែនត្រឹមតែការសួរសំណួរអំពីចំណុចអង្គហេតុ ដែលអង្គជំនុំជម្រះកំណត់ឲ្យធ្វើសវនាការនាពេលបច្ចុប្បន្នឡើយ ប៉ុន្តែប្តូករួមទាំងចំណុចទាំងអស់ពាក់ព័ន្ធនឹងសំណុំរឿង ០០២/០១ (ដើម្បីបញ្ចៀសការកោះហៅអ្នកជំនាញជាថ្មីនៅពេលក្រោយដែលពុំចាំបាច់) គ) សិទ្ធិរបស់ជនជាប់ចោទក្នុងការនៅស្ងៀមមិនឆ្លើយ (កថាខណ្ឌ ១៣) និង ឃ) បន្ទុកនៃការបង្ហាញភស្តុតាងរបស់សហព្រះរាជអាជ្ញា (កថាខណ្ឌ ១៩)។